ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

TONLE SAP AUTHORITY

អាជ្ញាធរទន្លេសាប

លេខ :....៤៥៤......អទស

# សេចក្តីសម្រេច
# ស្តីពី
# ការបង្កើតក្រុមការងារបច្ចេកទេស ដើម្បីកំណត់រៀបចំក្របខណ្ឌយុទ្ធសាស្ត្រ សម្រាប់អាងបឹងទន្លេសាប នៃកម្មវិធីការអនុវត្តវាយតម្លៃសន្តិសុខទឹក ក្រោមកិច្ចសហប្រតិបត្តិការជំនួយគាំទ្រ ធនាគារពិភពលោក

## រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម
## និងជា ប្រធានអាជ្ញាធរទន្លេសាប

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងធនធានទឹក និងឧតុនិយម
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០៩/៧០៥ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៩ ស្តីពីការបង្កើតអាជ្ញាធរទន្លេសាប
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣១០/២៥៨ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១០ ស្តីពីការកែសម្រួលមាត្រា ៣ មាត្រា ៥ មាត្រា ៦ មាត្រា ៩ មាត្រា ១០ និងមាត្រា ១២ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៦០៩/៧០៥ ចុះថ្ងៃទី ២៩ ខែមិថុនា ឆ្នាំ ២០០៩ ស្តីពីការបង្កើតអាជ្ញាធរទន្លេសាប
- បានឃើញអនុក្រឹត្យលេខ ៥៨ អនក្រ.បក ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងធនធានទឹក និងឧតុនិយម
- បានឃើញអនុក្រឹត្យលេខ ១១៦ អនក្រ.បក ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប
- យោងតាមតម្រូវការចាំបាច់របស់អាជ្ញាធរទន្លេសាប

## សម្រេច

**ប្រការ ១.**_

ត្រូវបានបង្កើតក្រុមការងារបច្ចេកទេស ដើម្បីកំណត់រៀបចំក្របខណ្ឌយុទ្ធសាស្ត្រ សម្រាប់អាងបឹងទន្លេសាប នៃកម្មវិធីការអនុវត្តវាយតម្លៃសន្តិសុខទឹក ដែលមានសមាសភាពដូចខាងក្រោម ៖

| | | | |
|---|---|---|---|
| ១. | ឯកឧត្តម **ហៀល តូនី** | អនុប្រធានក្តាប់រួម អាជ្ញាធរទន្លេសាប | ប្រធាន |
| ២. | ឯកឧត្តម **សរ គឹមសាន្ត** | អគ្គលេខាធិការ អាជ្ញាធរទន្លេសាប | អនុប្រធាន |
| ៣. | ឯកឧត្តម **ជា សុខនី** | អគ្គលេខាធិការរង អាជ្ញាធរទន្លេសាប | អនុប្រធាន |
| ៤. | លោក **ឡុក សីលា** | ប្រធាននាយកដ្ឋានរដ្ឋបាល ផែនការ និងសហប្រតិបត្តិការ | សមាជិក |
| ៥. | លោក **ហេង បូរាណា** | អនុប្រធាននាយកដ្ឋានត្រួតពិនិត្យការធ្វើអាជីវកម្ម និងអភិរក្ស | សមាជិក |
| ៦. | លោកស្រី **ប្រាក់ ចាន់ថវ្ណូនា** | អនុប្រធាននាយកដ្ឋានធនធានធម្មជាតិ | សមាជិក |
| ៧. | លោកស្រី **ឆេស សុជាទី** | អនុប្រធាននាយកដ្ឋានរដ្ឋបាល ផែនការ និងសហប្រតិបត្តិការ | សមាជិក |
| ៨. | លោក **លឹម ហេង** | អនុប្រធាននាយកដ្ឋាននីតិកម្ម និងផ្សព្វផ្សាយ | សមាជិក |
| ៩. | លោក **ខូច ទេងសុខ** | ប្រធានការិយាល័យធនធានរ៉ែ | សមាជិក |
| ១០. | លោក **អ៊ូ ទូច** | ប្រធានការិយាល័យត្រួតពិនិត្យការធ្វើអាជីវកម្មលើធនធានធម្មជាតិ | សមាជិក |
| ១១. | លោក **ឡូញ ណារិន្ទ** | ប្រធានការិយាល័យកសិកម្មចម្រុះ | សមាជិក |
| ១២. | លោក **សុខ វ៉ាយ៉ុង** | ប្រធានការិយាល័យអភិរក្ស | សមាជិក |
| ១៣. | លោក **អុល សុជាតិ** | ប្រធានការិយាល័យសម្របសម្រួលវិវាទ | សមាជិក |
| ១៤. | លោក **អៀ ច័ន្ទរិទ្ធ** | អនុប្រធានការិយាល័យនីតិកម្ម | សមាជិក |

**ប្រការ ២.**_

ក្រុមការងារបច្ចេកទេស មានភារកិច្ច ដូចខាងក្រោម ៖

- សម្របសម្រួលកិច្ចការបច្ចេកទេសជាមួយបណ្តាក្រសួងស្ថាប័នពាក់ព័ន្ធ ប្រកបដោយស្មារតីបុរេសកម្ម ស្របតាមផែនការនៃការចូលរួមរបស់ភាគីពាក់ព័ន្ធ សម្រាប់ការកសាងផែនការ និងវាយតម្លៃលើការវិនិច្ឆ័យសន្តិសុខទឹកទន្លេសាប
- សហការយ៉ាងជិតស្និតជាមួយក្រុមការងារធនាគារពិភពលោក World Bank Group, WBG ក្រសួងការបរទេស និងពាណិជ្ជកម្ម Department of Foreign Affairs and Trade, DFAT និងអង្គការភាពជាដៃគូទឹកអូស្ត្រាលី Australian Water Partnership, AWP របស់ប្រទេសអូស្ត្រាលី ក្នុងការអនុវត្តការវាយតម្លៃលើការវិនិច្ឆ័យសន្តិសុខទឹក ការកសាងសមត្ថភាពបច្ចេកទេស និងជំនាញ
- ចូលរួមពិនិត្យតាមដានលើវឌ្ឍនភាពសកម្មភាពការងារ និងរៀបចំសកម្មភាពការងារបន្ត បន្ទាប់ពីទទួលបានលទ្ធផលនៃការវាយតម្លៃលើការវិនិច្ឆ័យសន្តិសុខទឹក ការពិគ្រោះយោបល់ក្នុងវេទិកាពហុភាគីពាក់ព័ន្ធ និងការសម្រេចចិត្តរបស់អាជ្ញាធរទន្លេសាប
- ត្រួតពិនិត្យ និងគាំទ្រដល់ក្រុមការងារទីប្រឹក្សាបច្ចេកទេស ដែលធ្វើការវាយតម្លៃលើការវិនិច្ឆ័យ រួមជាមួយការកសាងផែនការ និងការសិក្សាបច្ចេកទេសដែលពាក់ព័ន្ធផ្សេងទៀត
- គាំទ្រដល់ដំណើរការការងារគ្រប់គ្រងរបស់ អាជ្ញាធរទន្លេសាប ក្នុងការសម្របសម្រួល និងការរៀបចំឱ្យមានភាពប្រទាក់ក្រឡាគ្នាជាមួយគម្រោង/កម្មវិធីផ្សេងទៀតរបស់ធនាគារពិភពលោក និងក្រសួងការបរទេស និងពាណិជ្ជកម្មរបស់ប្រទេសអូស្ត្រាលី ក៏ដូចជាសកម្មភាព/កម្មវិធីរបស់រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ដែលពាក់ព័ន្ធ
- ចូលរួមផ្តល់យោបល់លើការសិក្សា និងរៀបចំក្របខណ្ឌយុទ្ធសាស្ត្រ និងក្របខណ្ឌតាមដាន ត្រួតពិនិត្យ និងវាយតម្លៃនៃការអនុវត្តផែនការយុទ្ធសាស្ត្រ សម្រាប់អាងបឹងទន្លេសាប
- រៀបចំរបាយការណ៍វឌ្ឍនភាពការងារជូន **ឯកឧត្តមប្រធានអាជ្ញាធរទន្លេសាប** ដើម្បីពិនិត្យ សម្រេច និងផ្តល់អនុសាសន៍ណែនាំ
- បំពេញភារកិច្ចផ្សេងៗទៀត តាមការប្រគល់ជូនដោយ **ឯកឧត្តមប្រធានអាជ្ញាធរទន្លេសាប** ។

**ប្រការ ៣._**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៤._**

អនុប្រធាន អគ្គលេខាធិការ អគ្គលេខាធិការរង ទីប្រឹក្សា គ្រប់ប្រធាននាយកដ្ឋានចំណុះឱ្យអគ្គលេខាធិការដ្ឋានអាជ្ញាធរទន្លេសាប និងសាមីខ្លួន ដូចមានចែងក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ថ្ងៃសុក្រ ១១កើតខែភទ្របទ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០២៤

**រដ្ឋមន្ត្រី**

**និងជា ប្រធានអាជ្ញាធរទន្លេសាប**

**ថោ_ជេដ្ឋា**